ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No : 145
Date: 30.03.11. Time: 11:40
For : GMAC

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤៥/១១ ក.ប/ប្រ.ក

រាជធានីភ្នំពេញ.ថ្ងៃទី ២៩ ខែ ៣ ឆ្នាំ២០១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារបានជ្រាបថា យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ ១៩៦ កប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០១១ សូមលោក លោកស្រី អនុញ្ញាតឲ្យកម្មករនិយោជិតទាំងអស់របស់ខ្លួនឈប់សម្រាក ដោយមានប្រាក់ឈ្នួលនាឱកាសបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ក្នុងរយៈពេលបីថ្ងៃ គឺថ្ងៃទី១៤. ១៥ និងថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១១។

ក្រសួងសូមបញ្ជាក់ថា ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថាន មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួលជាមួយកម្មករនិយោជិតឲ្យមានការស្ម័គ្រចិត្ត ព្រមទាំងបែងចែកឲ្យមានពេលវេលា និងថ្ងៃឈប់សម្រាកបុណ្យបានសមស្រប។

កម្មករ និយោជិតដែលធ្វើការថ្ងៃឈប់បុណ្យចូលឆ្នាំនេះ មានសិទ្ធិទទួលនូវប្រាក់បំណាច់បន្ថែម ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា។

ក្នុងករណីមានលទ្ធភាព ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន គួរចាត់តាំងឲ្យមានការលេងល្បែងកំសាន្តនានា នៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំ និងដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករនិយោជិតដែលបានបំពេញការងារកន្លងមកផង។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមជឿជាក់ថា លោក លោកស្រី ដែលជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះ បានល្អត្រឹមត្រូវជាពុំខាន។

រដ្ឋមន្ត្រី
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

វង សូត

**ចម្លងជូនៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប "
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "
-សមាគមនិយោជក
-សហព័ន្ធសហជីព កម្មករនិយោជិត
"ដើម្បីជ្រាប និងអនុវត្ត "
-កាលប្បវត្តិ និងឯកសារ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩